ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន
លេខៈ ០៦៧/១៦ របក អ.ជ.ប.គ.ញ

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០១៦

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែមីនា ឆ្នាំ២០១៦ និងទិសដៅការងារ ខែមេសា ឆ្នាំ២០១៦

(ពីថ្ងៃទី២៦/០២/២០១៦ - ២៥/០៣/២០១៦)

យោងតាមផែនការសកម្មភាពនៃទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ដែលបានដាក់ចេញកាលពីខែកុម្ភៈ ឆ្នាំ២០១៦កន្លងទៅ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តអនុវត្តការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងគោលដៅចូលរួមចំណែកអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងលើកកម្ពស់សុខុមាលភាពជូនប្រជាពលរដ្ឋ ។ តាមរយៈការអនុវត្តផែនការសកម្មភាពនៃទិសដៅការងារខាងលើ នៅក្នុងខែមីនានេះ យើងបានធ្វើការកត់សម្គាល់ទៅលើសភាពការណ៍ និងអនុវត្តការងារទទួលបានលទ្ធផលដូចខាងក្រោម ៖

## I. សភាពការណ៍គ្រឿងញៀន

ក្នុងខែមីនាឆ្នាំ២០១៦នេះ អគ្គស្នងការដ្ឋាននគរបាលជាតិ ដែលមាន មន្ទីរប្រឆាំងគ្រឿងញៀន និងស្នងការដ្ឋាននគរបាល ២៤ រាជធានី ខេត្ត (លើកលែងខេត្តកែប) និងបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី ខេត្តចំនួន ១៧ (លើកលែងខេត្តចំនួន ៨ ដូចមានក្នុងតារាងឧបសម្ព័ន្ធទី៣) បានបើកកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀនទទួលបានលទ្ធផលល្អប្រសើរ ។ ក្នុងចំណោមបទល្មើសគ្រឿងញៀន ដែលបង្ក្រាបបាននៅក្នុងខែមីនានេះ មានបទល្មើសជួញដូរគ្រឿងញៀនសំយោគ ATS ចំនួន ៣ ករណីធំៗ ដែលបង្ក្រាបដោយ ៖

- មន្ទីរប្រឆាំងគ្រឿងញៀនចំនួន ២ ករណី និងចាប់យកមេតំហ្វេតាមីនក្រាមម្សៅ (ICE) និងមេតំហ្វេតាមីនគ្រាប់ (WY) ប្រមាណ ១ គ.ក្រ ៨១៨ ក្រាម
- កងរាជអាវុធហត្ថរាជធានីភ្នំពេញ ១ ករណី និងចាប់យកមេតំហ្វេតាមីនក្រាមម្សៅ (ICE) និងមេតំហ្វេតាមីនគ្រាប់ (WY) ប្រមាណ ២២ គ.ក្រ ៩៤៣ ក្រាម

គ្រឿងញៀនសំយោគ ATS ចាប់យកទាំង៣ករណីនេះ សរុបមានចំនួន ២៤ គ.ក្រ ៧៦១ ក្រាម លើចំនួនរួមដែលបានចាប់យកប្រមាណ ២៥ គ.ក្រ ៨៨១ ក្រាម ។ គួរឱ្យកត់សម្គាល់ បទល្មើសដែលបង្ក្រាបដោយកងរាជអាវុធហត្ថរាជធានីភ្នំពេញ គឺជាបទល្មើសជួញដូរគ្រឿងញៀនដែលមានការរៀបចំជាប្រព័ន្ធ រវាងទណ្ឌិតនៅក្នុងពន្ធនាគារ (ជនជាតិនីហ្សេរីយ៉ា ហ្គាណា វៀតណាម) ជាមួយមុខសញ្ញាជួញដូរគ្រឿងញៀននៅខាងក្រៅពន្ធនាគារ ។ ក្រោយពីការរកឃើញមុខសញ្ញានៅក្នុងពន្ធនាគារ សមត្ថកិច្ចកងរាជអាវុធហត្ថ ក៏បានបន្តឃាត់ខ្លួនជនសង្ស័យនៅក្រៅពន្ធនាគារចំនួន ៤ នាក់ បន្ថែមទៀត ដែលក្នុងនោះ មានជនជាតិវៀតណាម ០២ នាក់, កូរ៉េ ០១ នាក់ និង ជប៉ុន ០១ នាក់ ។



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone, Fax: (855) 23 721 648, Fax: (855) 23 727 529 P.O.Box: 151
E-mail: info@nacd.gov.kh Website : www.nacd.gov.kh

## II. អំពីការងារដឹកនាំ

### ក. ការងារដឹកនាំរបស់ស្ថាប័នកំពូលថ្នាក់ជាតិ

រាជរដ្ឋាភិបាល បានចេញអនុក្រឹត្យលេខ ៣៣ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដូចមានខ្លឹមសារអនុក្រឹត្យទាំងស្រុងនៅក្នុងតារាងឧបសម្ព័ន្ធទី៣ ។

### ខ. ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

- ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តដឹកនាំ និងណែនាំលើការងារជាគោលសំខាន់ៗសម្រាប់អនុវត្តនៅក្នុងខែមីនានេះ ក៏ដូចជាបណ្តាខែខាងមុខ មានដូចតទៅ ៖

១. **ការងារអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន ៖** ត្រូវរៀបចំកម្មវិធីអប់រំផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ និងរៀបចំកិច្ចប្រជុំដើម្បីពង្រឹងលើការងារត្រួតពិនិត្យគ្រឿងញៀននៅខេត្តកោះកុង ។

២. **ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងការចាកចេញពីគ្រឿងញៀន ៖** ក្រសួងសុខាភិបាលត្រូវគិតគូររៀបចំបង្កើតមណ្ឌលសុខភាព នៅក្នុងមណ្ឌលឱកាសខ្ញុំ ។ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវពិភាក្សាជាមួយអគ្គនាយកដ្ឋានពន្ធនាគារ ពាក់ព័ន្ធនឹងការព្យាបាលពិរុទ្ធជន-ទណ្ឌិតដែលញៀនគ្រឿងញៀននៅតាមមន្ទីរអប់រំកែប្រែនិងពន្ធនាគារ និងចុះពិនិត្យ ប្រមូលព័ត៌មាន នៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពនានា ដើម្បីចងក្រងជាឯកសារពាក់ព័ន្ធនឹងការព្យាបាល ថែទាំអ្នកញៀនគ្រឿងញៀន ។

៣. **ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់ ៖** ត្រូវបន្តពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់តាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ (CBT) និងតាមមេរៀនក្នុងប្រព័ន្ធអេឡិចត្រូនិច (E-Learning) និងពង្រឹងយន្តការការងាររបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ។

៤. **ការត្រួតពិនិត្យសារធាតុគីមីផ្សំ ៖** ត្រូវរៀបចំផែនការ និងយន្តការដាក់លាក់សម្រាប់គ្រប់គ្រង ត្រួតពិនិត្យតាមដានលើការនាំចូល និងការប្រើប្រាស់សារធាតុគីមីផ្សំ និងបន្តប្រមូលព័ត៌មានពាក់ព័ន្ធការប្រើប្រាស់សារធាតុញៀនថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ។

៥. **កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ៖** ត្រូវបន្តកិច្ចសហប្រតិបត្តិការជាមួយភាគីថៃ ឡាវ និងវៀតណាម ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន និងបន្តអនុវត្តនូវរាល់កិច្ចការដែលបានព្រមព្រៀងគ្នាកន្លងមក ។

៦. **កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា ៖** ត្រូវបន្តអនុវត្តនូវរាល់កិច្ចព្រមព្រៀងនានា ជាអាទិ៍ អនុស្សរណៈនៃការយោគយល់គ្នាក្នុងមហាអនុតំបន់ទន្លេមេគង្គឆ្នាំ១៩៩៣, ការបន្តអនុវត្តផែនការ ៣ ឆ្នាំ សម្រាប់គម្រោងសម្របសម្រួលសុវត្ថិភាពទន្លេមេគង្គ (Safe Mekong Project), គម្រោងពង្រឹងប្រសិទ្ធភាពការិយាល័យទំនាក់ទំនងព្រំដែនតាមដងទន្លេមេគង្គ (Mekong Project) របស់សាធារណរដ្ឋកូរ៉េ ។

៧. **ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៖** ត្រូវពន្លឿនការរៀបចំផែនការជាតិ៣ឆ្នាំ (២០១៦-២០១៨) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ព្រមទាំងបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងត្រូវចុះជួយពង្រឹងរាជធានី-ខេត្ត ក្នុងការអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

- ឯកឧត្តម អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការព្រំដែនទូទៅ (GBC) កម្ពុជា-ថៃ លើកទី១១ ពីថ្ងៃទី២១-២៤ ខែមីនា ឆ្នាំ២០១៦ នៅទីក្រុងបាងកក ប្រទេសថៃ ។

## III. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

តាមប្រសាសន៍ណែនាំរបស់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ និងទិសដៅដែលបានដាក់ចេញកាលពីខែកុម្ភៈ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានបន្តអនុវត្តការងារទទួលលទ្ធផលដូចខាងក្រោម ៖

### ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

- **ការងារអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ ៖** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានរៀបចំ និងអញ្ជើញតំណាងអធិការដ្ឋាននគរបាលខណ្ឌចំនួន ០២ ក្នុងរាជធានីភ្នំពេញ ដើម្បីផ្តល់កិច្ចសម្ភាសន៍នៅស្ថានីយទូរទស្សន៍ CNC តាមកម្មវិធីដូចតទៅ ៖
  - កម្មវិធីព័ត៌មានពេលថ្ងៃ (ដោយតំណាងអធិការដ្ឋាននគរបាលខណ្ឌមានជ័យ) ស្តីពីការបង្ការ បង្ក្រាប និងដោះស្រាយរាល់បញ្ហាគ្រឿងញៀនក្នុងភូមិសាស្ត្រខណ្ឌមានជ័យ ថ្ងៃទី២៣/០៣/២០១៦
  - កម្មវិធីសភាអ៊ីនធ័ណែត (ដោយតំណាងអធិការដ្ឋាននគរបាលខណ្ឌ៧មករា) ស្តីពីការបង្ការ បង្ក្រាប និងដោះស្រាយរាល់បញ្ហាគ្រឿងញៀនក្នុងភូមិសាស្ត្រខណ្ឌ៧មករា ថ្ងៃទី២៣/០៣/២០១៦ ។
- **ការងារអប់រំតាមសហគមន៍ ៖** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ, ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តចំនួន ៥ បានចុះអប់រំផ្សព្វផ្សាយពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមមូលដ្ឋានរបស់ខ្លួន ដែលមានខ្លឹមសារនៅក្នុងតារាងឧបសម្ព័ន្ធទី១ ។ លទ្ធផលជារួមមានមហាជនចូលរួមប្រមាណ **១៦៣.៤២៧** នាក់ ។ ក្នុងនោះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានចូលរួមអនុវត្តដូចខាងក្រោម ៖

១. បានរៀបចំកិច្ចប្រជុំជាមួយអង្គការដៃគូពាក់ព័ន្ធ កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៦ ដើម្បីពិភាក្សាការងារ និងស្វែងរកការគាំទ្រ សម្រាប់ការអប់រំផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់ និងគ្រោះថ្នាក់ នៃគ្រឿងញៀន ដែលត្រៀមរៀបចំនៅខេត្តកោះកុង (មន្ត្រីអគ្គលេខាធិការដ្ឋាន ០៥ រូប, មន្ត្រីសរុប ១៥ រូប)

២. បានសហការជាមួយក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចុះធ្វើការអប់រំផ្សព្វផ្សាយស្តីពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ពីថ្ងៃទី២៨ ខែកុម្ភៈ ដល់ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ (មហាជនចូលរួម ៣៩០ នាក់)

៣. បានសហការ សម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីបង្កើនការងារអប់រំផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ ។

៤. សហការជាមួយអគ្គនាយកដ្ឋានវិទ្យុ-ទូរទស្សន៍រដ្ឋ-ឯកជន, គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត និងក្រុមហ៊ុនឯកជន ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន តាមរយៈការផ្សាយពាណិជ្ជកម្មនៅតាមបណ្តាខេត្តនានា (ដូចមានសកម្មភាពនៅក្នុងតារាងឧបសម្ព័ន្ធទី១)

៥. ធនាគារអេស៊ីលីដា បានផ្តល់ដល់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នូវ (ខិត្តប័ណ្ណ ១០.០០០ សន្លឹក, ផ្ទាំងរូបភាព ១.០០០ ផ្ទាំង) សម្រាប់ការងារអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន

៦. បាន និងកំពុងបន្តដំណើរការផលិតផ្ទាំងប៉ាណូអប់រំពីបញ្ហាគ្រឿងញៀន សម្រាប់ដាក់នៅតាមតំបន់ព្រំដែន កម្ពុជា-ឡាវ

៧. បានចូលរួមប្រជុំជាមួយអគ្គនាយកដ្ឋានពន្ធនាគារ ដើម្បីរៀបចំយន្តការក្រុមការងារចុះពង្រឹង និងគ្រប់គ្រងមណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី-ខេត្ត កាលពីថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦

៨. តាមរយៈគេហទំព័ររបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (www.nacd.gov.kh) ក្នុងខែមីនា ឆ្នាំ២០១៦ មានការចូលអានប្រមាណ **៣១.៨៨៧** ដង ។

## ២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

### ២.១. ការកាត់បន្ថយគ្រោះថ្នាក់ ៖

២.១.១. បានចូលរួមសិក្ខាសាលាបណ្តុះបណ្តាលស្តីពី វិធីសាស្ត្រសិក្សាស្រាវជ្រាវទាក់ទងនឹងសុខភាពផ្លូវចិត្ត និងគ្រឿងញៀន កាលពីថ្ងៃទី១៤-១៨ ខែមីនា ឆ្នាំ២០១៦ ដែលរៀបចំដោយអង្គការ FHI360

២.១.២. បានចូលរួមផ្តល់យោបល់លើនិយាមប្រតិបត្តិនៃការផ្តួចផ្តើមភាពជាដៃគូ រវាងក្រុមប្រឈមមុខខ្ពស់នឹងមេរោគអេដស៍ ជំងឺអេដស៍ និងសហគមន៍ (MCPI) ដែលបាននិងកំពុងរៀបចំដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦

២.១.៣. បានចូលរួមពិធីផ្សព្វផ្សាយ និងដាក់ឱ្យប្រើប្រាស់ផែនការយុទ្ធសាស្ត្រជាតិ (២០១៦-២០២០) ស្តីពីការកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន របស់ក្រសួងសុខាភិបាល និងធ្វើបទបង្ហាញក្នុងឱកាសនោះ ស្តីពីគោលនយោបាយ និងគោលការណ៍ណែនាំសម្រាប់អនុវត្តកម្មវិធីម្ជុល/សឺរាំង កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ (មន្ត្រីអគ្គលេខាធិការដ្ឋាន ០៣ រូប)

២.១.៤. ក្រសួងសុខាភិបាល បានបោះពុម្ពផែនការយុទ្ធសាស្ត្រជាតិ (២០១៦-២០២០) ស្តីពីការកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន ចំនួន ២០០ ក្បាល

២.១.៥. បានចូលរួមប្រជុំលើកទី១ សម្រាប់ឆ្នាំ២០១៦ តាមការអញ្ជើញរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីប្រកាសសមាសភាពនៃគណៈកម្មការ សម្របសម្រួលត្រីភាគីប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀននៅកន្លែងធ្វើការ កាលពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ (មន្ត្រីអគ្គលេខាធិការដ្ឋាន ០២ រូប) ។

### ២.២. ការព្យាបាល និងស្តារនីតិសម្បទា

២.២.១. បានចុះទៅពិនិត្យ និងប្រមូលព័ត៌មាន ពីថ្ងៃទី០៦ ដល់ ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ នៅមណ្ឌលសុខភាពអូរអំបិល, ទឹកថ្លា, ម៉ាឡៃ, មណ្ឌលជីវិតថ្មីភ្នំបាក់, មណ្ឌលកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ, មណ្ឌលសុខភាពទួលតាឯក, ចំការសំរោង, មណ្ឌលកងរាជអាវុធហត្ថខេត្តបាត់ដំបង និងមណ្ឌលឱកាសខ្ញុំ, មណ្ឌលសុខភាពផ្សារដើមថ្កូវ, មន្ទីរពេទ្យបង្អែកជ័យជំនះ រាជធានីភ្នំពេញ ដើម្បីចងក្រងជាឯកសារពាក់ព័ន្ធនឹងការងារព្យាបាល និងថែទាំអ្នកញៀនគ្រឿងញៀន (មន្ត្រីសរុប ១២ រូប, មន្ត្រីអគ្គលេខាធិការដ្ឋាន ០៣ រូប)

២.២.២. បានប្រជុំពិភាក្សាការងារ រវាងក្រុមលេខាធិការដ្ឋាន នៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ជាមួយអគ្គនាយកដ្ឋានពន្ធនាគារ ដើម្បីចុះពិនិត្យផ្ទាល់នៅតាមមន្ទីរអប់រំ និងពន្ធនាគារមួយចំនួនពាក់ព័ន្ធនឹងការងារព្យាបាល ស្តារនីតិសម្បទាពិរុទ្ធជន-ទណ្ឌិត ដែលញៀនគ្រឿងញៀន កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ (មន្ត្រីពាក់ព័ន្ធសរុប ១៨ រូប, មន្ត្រី អគ្គលេខាធិការដ្ឋាន ០៣ រូប)

២.២.៣. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បាននិងកំពុងពង្រឹងលើការងារស្តារនីតិសម្បទា និងបណ្តុះបណ្តាលវិជ្ជាជីវៈដល់អ្នកញៀនគ្រឿងញៀននៅតាមមណ្ឌលបណ្តោះអាសន្ន

២.២.៤. បានចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ ០១ រូប ទៅចូលរួមសិក្ខាសាលា ស្តីពីស្តង់ដារអភិវឌ្ឍន៍ការព្យាបាលដោយផ្អែកលើសហគមន៍ក្នុងតំបន់អាស៊ាន កាលពីថ្ងៃទី០២-០៤ ខែមីនា ឆ្នាំ២០១៦ នៅទីក្រុងបាងកក ប្រទេសថៃ (មន្ត្រីអគ្គលេខាធិការដ្ឋាន ០១ រូប) ។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

### ៣.១. ការពង្រឹងសមត្ថភាពភ្នាក់ងារអនុវត្តន៍ច្បាប់

៣.១.១. បានបើកវគ្គបណ្តុះបណ្តាលតាមមេរៀនក្នុងប្រព័ន្ធអេឡិចត្រូនិច (E-Learning) ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែន ដល់មន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ចំនួន ១០ រូប កាលពីថ្ងៃទី០៩-១១ ខែមីនា ឆ្នាំ២០១៦

៣.១.២. បានបើកវគ្គបណ្តុះបណ្តាលមន្ត្រី នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ចំនួន ១២ រូប ស្តីពីការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់តាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ (CBT) វគ្គទី១/ឆ្នាំ២០១៦ កាលពីថ្ងៃទី២១-២៥ ខែមីនា ឆ្នាំ២០១៦ នៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ

៣.១.៣. បានសហការជាមួយអង្គការ UNODC រៀបចំកិច្ចប្រជុំ លើកទី៨ នៃគណៈកម្មការប្រឹក្សាយោបល់គម្រោងស្តីពី ភាពជាដៃគូនៃមន្ត្រីអនុវត្តន៍ច្បាប់ក្នុងតំបន់ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន (PATROL) កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ ២០១៦ ដើម្បីរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តបន្តក្នុងឆ្នាំ២០១៦ (អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ០៦ រូប, មន្ត្រីសរុប ១៥ រូប)

៣.១.៤. បានសម្របសម្រួលជាមួយក្រសួងសមាជិក ដើម្បីចាត់បញ្ជូនមន្ត្រីជាតំណាងចំនួន ០២ រូប (អគ្គស្នងការដ្ឋាននគរបាលជាតិ និង អគ្គនាយកដ្ឋានគយនិងរដ្ឋាករ) ទៅចូលរួមកិច្ចប្រជុំក្រុមការងារអន្តរវិស័យអនុវត្តន៍ច្បាប់ (កម្រិតថ្នាក់ប្រតិបត្តិ) ក្នុងក្របខ័ណ្ឌ ASOD (ASEAN Senior Officials on Drug Matters) ពីថ្ងៃទី០២-០៣ ខែមីនា ឆ្នាំ២០១៦ នៅ ប្រទេសសឹង្ហបុរី

៣.១.៥. សហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តព្រះវិហារ សិក្សាពីលក្ខណៈភូមិសាស្ត្រ នៃស្រុកជាំក្សាន្ត ដើម្បីរៀបចំបង្កើតការិយាល័យទំនាក់ទំនងព្រំដែន (BLO)

៣.១.៦. បានរៀបចំដំឡើងម៉ាស៊ីនវិភាគគ្រឿងញៀនប្រភេទ GC នៅក្នុងមន្ទីរពិសោធន៍គ្រឿងញៀនរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ

៣.១.៧. ខេត្តមណ្ឌលគិរី បានប្រជុំតាមការផ្លាស់វេនជាមួយខេត្តដាក់ឡាក់ (វៀតណាម) បានចំនួន ០២ លើក ដើម្បីផ្លាស់ប្តូរសភាពការណ៍ បទពិសោធន៍ និងលើកទិសដៅការងារអនុវត្តបន្ត ៖

- លើកទី១ ធ្វើនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ នៅបញ្ជាការដ្ឋានកងទ័ពការពារព្រំដែនខេត្តដាក់ឡាក់ សមាសភាពខាងភាគីនគរបាលកម្ពុជា សរុប ២៧ រូប ខាងភាគីកងទ័ពព្រំដែនខេត្តដាក់ឡាក់ ១០ រូប
- លើកទី២ ធ្វើនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៦ នៅស្នងការដ្ឋាននគរបាលខេត្ត សមាសភាពខាងភាគីនគរបាលកម្ពុជា សរុប ២៩ រូប ខាងភាគីនគរបាលខេត្តដាក់ឡាក់ (វៀតណាម) ចំនួន ២២ រូប
- បានប្រជុំបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន និងការអនុវត្តផែនការប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន ប្រចាំត្រីមាសទី១ ដែលមានមន្ត្រីនគរបាលពាក់ព័ន្ធនៃស្នងការដ្ឋាននគរបាលខេត្ត និង អធិការ អធិការរង នាយ-នាយរងនគរបាលក្រុង-ស្រុក នាយនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់ សរុប ៣៥ នាក់ ។

### ៣.២. លទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀន

- **បទល្មើសគ្រឿងញៀន** សរុប **៣២១** ករណី លើ ៣១៩ ករណី នៃខែកុម្ភៈ ឆ្នាំ២០១៦
- **ជនសង្ស័យ** ឃាត់ខ្លួន សរុប **៧៥៧** នាក់ (ស្រី ៧៩ នាក់) លើ ៨៨៤ នាក់ នៃខែកុម្ភៈ ឆ្នាំ២០១៦
- ក្នុងបទល្មើសគ្រឿងញៀនទាំង ៣២១ ករណី និងជនសង្ស័យទាំង ៧៥៧ នាក់ ខាងលើគឺ ៖

- បទល្មើសគ្រឿងញៀនបង្ក្រាបដោយ សមត្ថកិច្ចនគរបាល **២៣៦** ករណី, ជនសង្ស័យ **៥៣៨** នាក់ (ស្រី ៦០ នាក់)
- បទល្មើសគ្រឿងញៀនបង្ក្រាបដោយ សមត្ថកិច្ចកងរាជអាវុធហត្ថ **៨៥** ករណី, ជនសង្ស័យ **២១៩** នាក់ (ស្រី ១៩ នាក់)

- ក្នុងចំនួនជនសង្ស័យ ៧៥៧ នាក់ ខាងលើមាន ០៦ សញ្ជាតិគឺ ខ្មែរ ៧៣៨ នាក់ (ស្រី ៧២ នាក់), វៀតណាម ១៥ នាក់ (ស្រី០៧នាក់), ថៃ ០១ នាក់ (ប្រុស), កូរ៉េ ០១ នាក់ (ប្រុស), ហ្វាំងឡង់ ០១ នាក់ (ប្រុស), ជប៉ុន ០១ នាក់ (ប្រុស) ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត

- **វត្ថុតាងគ្រឿងញៀនចាប់យក** ៖ មេតំហ្វេតាមីនក្រាមម្សៅ (ICE) ៥.៧១៨ ក្រាម ៣៦, មេតំហ្វេតាមីនគ្រាប់ WY ២០.១៦៣ ក្រាម, អ៊ិចស្តាស៊ី ២,៤៧ ក្រាម, កេតាមីន ៤,៨៣ ក្រាម, កញ្ឆាក្រៀម ២,៨៩ ក្រាម, ដើមកញ្ឆា ៧៨.៥៩៣ ដើម

- **ទ្រព្យសម្បត្តិសំខាន់ៗ** ពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនដែលបានចាប់យក ៖ ម៉ូតូ ១៣៤ គ្រឿង រថយន្ត ៥ គ្រឿង ប្រាក់កម្ពុជា ៧.២៧៥.១០០ រៀល ប្រាក់ថៃ ៤.០១០ បាត ប្រាក់អាមេរិក ១.៩៣៤ ដុល្លារ , ប្រាក់វៀតណាម ១០៥.០០០ ដុង, ប្រាក់ឡាវ ១៥.០០០ គីប (ដូចមានក្នុងតារាងឧបសម្ព័ន្ធទី៣)

- ជនសង្ស័យចាប់តាមដីកា មាន ១៣ ដីកា = ជនសង្ស័យ ១៣ នាក់ (ប្រុសជនជាតិខ្មែរ)

### ៣.៣. លទ្ធផលកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន

- សំណាកសង្ស័យជាគ្រឿងញៀនដែលបានធ្វើកោសល្យវិច័យក្នុង ខែមីនា ឆ្នាំ២០១៦ សរុប ២៤៣ ករណី = ២៦៦ សំណាក ក្នុងនោះ ៖

- **សំណាក វិជ្ជមានសារធាតុញៀន** មាន ២៣៩ ករណី = ២៥៣ សំណាក (៩៥,០៨ %)គឺ ៖
  - មេតំហ្វេតាមីន ICE ២២៥ សំណាក = ៨៤,៥៨ %
  - មេតំហ្វេតាមីន WY ២១ សំណាក = ៧,៨៩ %
  - ហេរ៉ូអ៊ីន ០១ សំណាក = ០,៣៧ %
  - កញ្ឆា ០១ សំណាក = ០,៣៧ %
  - កេតាមីន ០២ សំណាក = ០,៧៥ %
  - MDMA ០៣ សំណាក = ១,១២ %
- **សំណាក អវិជ្ជមានសារធាតុញៀន** ០៤ ករណី = ១៣ សំណាក (៤,៨៨ %)
  - បានផ្តល់ជូនដល់ ៖
    - អគ្គស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញនូវ តេស្តរកសារជាតុញៀនក្នុងទឹកនោម ៦៤០ តេស្ត
    - កងរាជអាវុធហត្ថរាជធានីភ្នំពេញនូវ តេស្តរកសារជាតុញៀនក្នុងទឹកនោម ២៤០ តេស្ត
    - ស្នងការដ្ឋាននគរបាលខេត្តពោធិ៍សាត់នូវ ស្រោមវេចខ្ចប់វត្ថុតាង ១០០ ស្រោម តេស្តរកសារជាតុញៀនក្នុងទឹកនោម ១៦០ តេស្ត
    - ស្នងការដ្ឋាននគរបាលខេត្តត្បូងឃ្មុំនូវ ស្រោមវេចខ្ចប់វត្ថុតាង ១០០ ស្រោម
    - បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តកំពង់ស្ពឺនូវ ម៉ាគ្នីតេស្ត ០១ ដប
    - មន្ទីរប្រឆាំងគ្រឿងញៀននូវ តេស្តរកសារជាតុញៀនក្នុងទឹកនោម ៣៦០ តេស្ត

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

### ៤.១. ការងារគ្រប់គ្រង និងត្រួតពិនិត្យសារធាតុគីមីផ្សំ

ក្នុងខែមីនា ឆ្នាំ២០១៦ ទិន្នន័យសារជាតុគីមីផ្សំពាក់ព័ន្ធនឹងតារាងទី IV នៃច្បាប់ស្តីពីការត្រួតពិនិត្យ

គ្រឿងញៀន ដែលបានអនុញ្ញាតឱ្យនាំចូល សរុបមាន **២៨៥.០០០** គ.ក្រ ក្នុងនោះ ៖

- មានអាជ្ញាប័ណ្ណឱ្យនាំចូលដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ចំនួន ៩៥.០០០ គ.ក្រ
- មានបទដ្ឋានបច្ចេកទេសឱ្យនាំចូលដោយក្រសួងឧស្សាហកម្មនិងសិប្បកម្ម ចំនួន ១៩០.០០០ គ.ក្រ

### ៤.២. ការងារបណ្តុះបណ្តាលសមត្ថភាព

៤.២.១. បានចាត់បញ្ជូនមន្ត្រីអនុវត្តន៍ច្បាប់កម្ពុជា ចំនួន ៣០ រូប (មន្ត្រីអគ្គលេខាធិការដ្ឋាន ០៨ រូប) ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការវិភាគសារធាតុគីមីផ្សំ ដែលគាំទ្រដោយការិយាល័យ នៃក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) កាលពីថ្ងៃទី១៣-១៦ ខែមីនា ឆ្នាំ២០១៦ នៅខេត្តស្រះកែវ ប្រទេសថៃ

៤.២.២. បានចាត់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ០១ រូប ចូលជាសមាជិកគណៈកម្មការអន្តរក្រសួង គ្រប់គ្រង និងត្រួតពិនិត្យទំនិញគ្រោះថ្នាក់ ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

៥.១. បានទំនាក់ទំនងជាមួយការិយាល័យនៃក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ពាក់ព័ន្ធនឹងការបង្កើតការិយាល័យទំនាក់ទំនងព្រំដែន (BLO) ច្រកជាំក្សាន្ត ខេត្តព្រះវិហារ ជាមួយច្រកណាំយឿន ខេត្តអ៊ូប៊ុនរ៉ាឆានី ប្រទេសថៃ

៥.២. បានបន្តអនុវត្តគម្រោងទ្វេភាគី ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ ២០១៥-២០១៦ ជាមួយការិយាល័យនៃក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB)

៥.៣. បានបន្តរៀបចំឯកសារចូលរួមកិច្ចប្រជុំការិយាល័យទំនាក់ទំនងព្រំដែន (BLO) កម្ពុជា-វៀតណាម លើកទី៣ ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

៦.១. បានរៀបចំកិច្ចប្រជុំគណៈកម្មការប្រឹក្សាយោបល់គម្រោង ស្តីពីភាពជាដៃគូនៃមន្ត្រីអនុវត្តន៍ច្បាប់ក្នុងតំបន់ប្រឆាំងទៅនឹងឧក្រិដ្ឋកម្មឆ្លងដែន និងឧក្រិដ្ឋកម្មគ្រឿងញៀន កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៦ ដើម្បីដាក់ចេញនូវផែនការសកម្មភាពគម្រោងសម្រាប់អនុវត្តបន្តក្នុងឆ្នាំ២០១៦

៦.២. បានរៀបចំបញ្ជូនសេចក្តីព្រាងអនុស្សរណៈ ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងសារធាតុញៀនប្រភេទថ្មីដែលប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និង ពិធីសារលើការទទួលយកអនុសាសន៍ស្តីពីការអនុវត្តរួមគ្នានៃវិធីសាស្ត្រត្រួតពិនិត្យគ្រឿងញៀនដោយមានការឃ្លាំមើល ទៅភាគីរុស្ស៊ី តាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

៧.១. ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានរៀបចំកិច្ចប្រជុំដើម្បីពិនិត្យលើសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

៧.២. បានស្នើសុំគោលការណ៍ពី ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ ដើម្បីរៀបចំឡើងវិញនូវសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀននៅខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ

៧.៣. បានចុះទៅខេត្តក្រចេះ, ត្បូងឃ្មុំ, ព្រៃវែង, កណ្តាល, តាកែវ, កំពត, កែប ដើម្បីរៀបចំយន្តការការងាររបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត និងពង្រឹងការអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ ០១ បប ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន

៧.៤. បានប្រជុំដើម្បីពិនិត្យលើសេចក្តីព្រាងផែនការជាតិ ៣ ឆ្នាំ (២០១៦-២០១៨) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន កាលពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ ។

## IV. ផែនការសកម្មភាពអនុវត្តទិសដៅត្រួតពិនិត្យគ្រឿងញៀន ខែមេសា ឆ្នាំ២០១៦

### ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

១.១. ត្រៀមរៀបចំពិធីអប់រំ ផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន និងរៀបចំកិច្ចប្រជុំដើម្បីពង្រឹងការងារត្រួតពិនិត្យគ្រឿងញៀន នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៦ នៅខេត្តកោះកុង

១.២. រៀបចំ និងអញ្ជើញតំណាងអធិការដ្ឋាននគរបាលក្រុង ចំនួន ២ ដើម្បីផ្តល់កិច្ចសម្ភាសន៍នៅស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី ដូចខាងក្រោម ៖

- អធិការដ្ឋាននគរបាលក្រុងតាខ្មៅ ខេត្តកណ្តាលដើម្បីផ្តល់បទសម្ភាសន៍ក្នុងកម្មវិធីព័ត៌មានពេលថ្ងៃ ស្តីពីការបង្ការ បង្ក្រាប និងដោះស្រាយរាល់បញ្ហាគ្រឿងញៀនក្នុងភូមិសាស្ត្រក្រុងតាខ្មៅ (ថ្ងៃ២៧/៤/២០១៦)
- អធិការដ្ឋាននគរបាលក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដើម្បីផ្តល់បទសម្ភាសន៍ក្នុងកម្មវិធីសភាអ៊ីនធ័រណែត ស្តីពីការបង្ការ បង្ក្រាប និងដោះស្រាយរាល់បញ្ហាគ្រឿងញៀនក្នុងភូមិសាស្ត្រក្រុងច្បារមន ខេត្តកំពង់ស្ពឺ (ថ្ងៃទី២៧/៤/២០១៦) ។

១.៣. បន្តរៀបចំកម្មវិធីប្រឡងតែងកំណាព្យ និងគូរគំនូរប្រឆាំងគ្រឿងញៀន

១.៤. បន្តសហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត និងបណ្តាក្រុមហ៊ុនឯកជន ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន នៅក្នុងកម្មវិធីប្រគំតន្ត្រីផ្សព្វផ្សាយពាណិជ្ជកម្មនានា

១.៥. សហការជាមួយក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចុះធ្វើការអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅស្រុកអង្គរជ័យ (ខេត្តកំពត) ក្រុងដូនកែវ និង ស្រុកបាទី (ខេត្តតាកែវ)

១.៦. ស្នើសុំទៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ LOLC និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ដើម្បីពិនិត្យលទ្ធភាពក្នុងការផ្តល់នូវខិត្តប័ណ្ណអប់រំផ្សព្វផ្សាយពីផលប៉ះពាល់នៃគ្រឿងញៀន និងគ្រោះថ្នាក់នៃគ្រឿងញៀន

១.៧. បន្តសហការជាមួយក្រសួងទេសចរណ៍ក្នុងការ ៖

- បញ្ជ្រាបខ្លឹមសារអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់ដែលបណ្តាលពីគ្រឿងញៀននៅក្នុងយុទ្ធនាការប្រឡងប្រណាំង ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ
- ចែកខិត្តប័ណ្ណអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រឿងញៀននៅតាមគោលដៅទេសចរណ៍

១.៨. បន្តជំរុញក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការបណ្តុះបណ្តាលក្រុមជនបង្គោលនៅតាមរោងចក្រ និងសហគ្រាស ។

### ២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

២.១. បន្តជំរុញសកម្មភាពផ្សព្វផ្សាយឱ្យកាន់តែសកម្មថែមទៀត ដើម្បីឱ្យអ្នករងគ្រោះដោយសារគ្រឿងញៀន បានដឹង និងទៅទទួលយកសេវាព្យាបាលនៅតាមមន្ទីរពេទ្យបង្អែក ឬមណ្ឌលសុខភាព ដែលនៅជិត

២.២. បន្តការកែសម្រួល និងពង្រឹងសមត្ថភាព គុណភាព នៃយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

២.៣. បន្តជំរុញគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ដើម្បីពង្រឹងយន្តការក្នុងការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ។

**៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់**

៣.១. សហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តរតនគិរី ធ្វើការសិក្សាពីទីតាំងដែលត្រូវរៀបចំបង្កើតការិយាល័យទំនាក់ទំនងព្រំដែន ដើម្បីផ្តល់ព័ត៌មានទៅអង្គការ UNODC

៣.២. ត្រៀមចាត់បញ្ជូនមន្ត្រី ២៣ រូប ទៅចូលរួមសិក្ខាសាលាស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ រវាងការិយាល័យទំនាក់ទំនងព្រំដែន (BLO) កម្ពុជា និងថៃ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី៣០ ខែមីនា ដល់ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ នៅខេត្តឈុនបុរី ប្រទេសថៃ

៣.៣. បន្តបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីកងរាជអាវុធហត្ថរាជធានីភ្នំពេញ ១២ រូប ស្តីពីការត្រួតពិនិត្យគ្រឿងញៀនតាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ (CBT) វគ្គទី២/២០១៦ ពីថ្ងៃទី០៤-០៨ ខែមេសា ឆ្នាំ២០១៦

៣.៤. បន្តបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀននិងឧក្រិដ្ឋកម្មឆ្លងដែនតាមមេរៀនក្នុងប្រព័ន្ធអេឡិចត្រូនិច (E-Learning)

៣.៥. ត្រៀមសហការជាមួយក្រសួងការពារជាតិ រៀបចំវគ្គបណ្តុះបណ្តាលការទប់ស្កាត់ ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ដល់កងឯកភាពនៃកងយោធពលខេមរភូមិន្ទ សម្រាប់ឆ្នាំ២០១៦

៣.៦. ត្រៀមរៀបចំកិច្ចប្រជុំត្រួតពិនិត្យយន្តការការងាររបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) នៅទូទាំងប្រទេស ។

**៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ**

៤.១. ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ ស្តីពីការគ្រប់គ្រង ត្រួតពិនិត្យការចរាចរ និងការប្រើប្រាស់សារធាតុគីមីផ្សំ

៤.២. ត្រៀមរៀបចំសេចក្តីព្រាងប្រកាសស្តីពី ការបិទស្លាកសញ្ញា ការទុកដាក់ ការវេចខ្ចប់នូវសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម (ដោយក្រសួងឧស្សាហកម្មនិងសិប្បកម្ម)

៤.៣. បន្តប្រមូលព័ត៌មានពាក់ព័ន្ធនឹងសារធាតុញៀនថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន**

៥.១. បន្តអនុវត្តគម្រោងទ្វេភាគី ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៥-២០១៦ ជាមួយការិយាល័យនៃក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB)

៥.២. ត្រៀមទទួលមន្ត្រីព័ត៌មានវិទ្យា (Information of Technology. IT) របស់ការិយាល័យនៃក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ដើម្បីពិភាក្សាក្នុងការរៀបចំបង្កើត Tele - Video Conference នៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ

៥.៣. ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការវិភាគគ្រឿងញៀនដោយម៉ាស៊ីន GC ដល់មន្ត្រីអនុវត្តន៍ច្បាប់ពាក់ព័ន្ធ

៥.៤. ត្រៀមពិធីទទួលសម្ភារជំនួយរបស់ការិយាល័យនៃក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB)

៥.៥. ត្រៀមចូលរួមកិច្ចប្រជុំការិយាល័យទំនាក់ទំនងព្រំដែន (BLO) កម្ពុជា-វៀតណាម លើកទី៣ ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងហូជីមិញ ប្រទេសវៀតណាម ។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា**

៦.១. ត្រៀមពិធីចុះហត្ថលេខាលើគម្រោងត្រួតពិនិត្យកុងតឺន័រ រវាង អ.ជ.ប.គ.៣ ជាមួយអង្គការ UNODC

៦.២. ត្រៀមទទួលតេស្តវិភាគគ្រឿងញៀន ពីគណៈកម្មាធិការជាតិត្រួតពិនិត្យគ្រឿងញៀនចិន (NNCC)

៦.៣. ត្រៀមសហការជាមួយអង្គការ UNODC ចុះធ្វើការសិក្សា វាយតម្លៃលើលទ្ធភាព និងតម្រូវការចាំបាច់ដើម្បីបង្កើតការិយាល័យទំនាក់ទំនងព្រំដែន (BLO) រវាងខេត្តរតនគិរី ជាមួយខេត្តអត្តពឺ (ឡាវ) និងខេត្តកន្ទុម (វៀតណាម) នៅថ្ងៃទី០៤-០៧ ខែមេសា ឆ្នាំ២០១៦ ។

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ**

៧.១. បន្តចុះពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀននៅខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ កំពង់ស្ពឺ ព្រះសីហនុ កោះកុង មណ្ឌលគិរី រតនគិរី កំពង់ចាម កំពង់ធំ សៀមរាប ឧត្តរមានជ័យ ព្រះវិហារ និងខេត្តស្ទឹងត្រែង

៧.២. រៀបចំសេចក្តីសម្រេចស្តីពី ការបង្កើតគណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀននៅខេត្តជាប់ព្រំដែន កម្ពុជា-ឡាវ

៧.៣. បន្តការរៀបចំសេចក្តីព្រាងផែនការជាតិ ៣ ឆ្នាំ (២០១៦-២០១៨) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

៧.៤. បន្តរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

៧.៥. រៀបចំលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធនឹងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**អគ្គលេខាធិការ**

**ចម្លងជូន**
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម កៅ ខុនដាក់ អនុប្រធាន អ.ជ.ប.គ.៣
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.៣
  " ដើម្បីជូនជ្រាប "
- ក្រសួង ស្ថាប័ន សមាជិក អ.ជ.ប.គ.៣
- ក្រសួងផែនការ
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត
- នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីមុខការ "
- ឯកសារ